# ការថ្វាយព្រះពរ និងសំណើ
# ព្រះរាជទានអន្តរាគមន៍

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ចំពោះព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម-
## សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

web site: hoksavann.org

សូមថ្វាយព្រះពរ,

អាត្មាបានទទួលរួចហើយ នូវព្រះចុតហ្មាយរបស់ព្រះអង្គ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៦របស់អាត្មា ដែលសំណើសុំព្រះអង្គ ព្រះមេត្តាជួយធ្វើអន្តរាគមន៍ទៅរាជរដ្ឋាភិបាលខ្មែរ សុំឲ្យដកពាក្យបណ្តឹងពីសកម្មជនសិទ្ធិមនុស្ស ពីសកម្មជនព្រំដែន លើកលែងទោសសមាជិកសភានៃគណបក្សប្រឆាំង និងលុបចោលនូវទោសឧក្រិដ្ឋក្នុងបទបរិហារកេរ្តិ៍ជាដើម ។

សូមអរព្រះគុណចំពោះព្រះរាជទានអន្តរាគមន៍ ក្នុងវិបត្តិនយោបាយខ្មែរ រហូតបានសំរេចជោគជ័យនេះ ។ ដោយអំពើជាកុសលនេះ សូមព្រះអង្គមានព្រះសុខភាពល្អបរិបូណ៌ មានព្រះជន្មយឺនយូរ ដើម្បីបន្តបំពេញអំពើជាកុសលនេះ ស្របតាមព្រះរាជសិទ្ធិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ។ ឆ្លៀតពេលនេះដែរ សូមអនុមោទនានូវវិធីដោះស្រាយរបស់រាជរដ្ឋាភិបាលខ្មែរ ក្នុងវិបត្តិនយោបាយខ្មែរ ឆ្លងតាមការសម្របសម្រួលគ្នាដោយសន្តិវិធី ស្របតាមមាគ៌ាព្រះពុទ្ធសាសនា ក្រោមឱវាទរបស់ព្រះមហាក្សត្រខ្លួននេះ ។

ជាមួយគ្នានេះ សូមព្រះអង្គព្រះមេត្តាព្រះរាជទានធ្វើអន្តរាគមន៍ទៅរាជរដ្ឋាភិបាល ចំពោះបញ្ហាដ៏សំខាន់បំផុត ដែលជាអាយុជីវិតរបស់ប្រទេសកម្ពុជាជា២ខដូចតទៅនេះ ៖

១- សូមគណបក្សនយោបាយខ្មែរទាំងបី ដែលទើបតែសម្របសម្រួលធ្វើការជាមួយគ្នាជាថ្មី គិតគូរឡើងវិញឲ្យបានខ្លាំងក្លាបំផុត អំពីបញ្ហាបាត់បង់ទឹកដីប្រទេសកម្ពុជា ជាពិសេសសូមធ្វើសំណូមពររាជរដ្ឋាភិបាលខ្មែរ អនុញ្ញាតឲ្យគណៈកម្មការព្រំដែនកម្ពុជារបស់រាជរដ្ឋាភិបាលខ្មែរ ជួបពិភាក្សាជាមួយគណៈកម្មាធិការព្រំដែនក

ម្ពុជានៅប្រទេសបារាំង និងគណៈកម្មការព្រំដែនកម្ពុជានៅប្រទេសខ្មែរ ព្រមទាំងតំណាងប្រជាពលរដ្ឋជាសាក្សី នៅព្រំដែនខ្មែរ-វៀតណាម ដែលបាននិយាយថា ដីស្រែរបស់ខ្លួនបានត្រូវវៀតណាមរំលោភយក ។ ជំនួបនេះមានប្រយោជន៍ដល់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលជាមួយមតិផ្ទុយ អំពីបញ្ហាទឹកដី ស្របតាមមធ្យោបាយសម្របសម្រួលដូចបានធ្វើកន្លងមកនេះ និងដើម្បីបានឯកសារនិងពត៌មានបន្ថែម ដើម្បីឲ្យរាជរដ្ឋាភិបាលធ្វើការឲ្យមានប្រសិទ្ធិភាព ជាមួយប្រទេសជិតខាងកុំឲ្យបាត់បង់ទឹកដី ។

២- សូមធ្វើសំណូមពរដល់រាជរដ្ឋាភិបាលខ្មែរ សូមបង្កើតក្រសួងអន្តោប្រវេសន៍ ទោះបីត្រូវចំណាចថវិកាជាតិក៏ដោយ ព្រោះវាមានប្រយោជន៍ចាំបាច់ ដើម្បីពិនិត្យមើល និងអនុវត្តតាមផ្លូវច្បាប់ជាតិនិងច្បាប់អន្តរជាតិ នូវជនអន្តោប្រវេសន៍ ដែលចូលមកប្រទេសកម្ពុជាដោយខុសច្បាប់ ជាពិសេសជនជាតិវៀតណាម ដែលត្រូវអ្នកស្រាវជ្រាវបរទេសនៅកម្ពុជាពោលថា ជនជាតិវៀតណាមបានចូលមកប្រទេសកម្ពុជាសព្វថ្ងៃរហូតដល់៤លានកន្លះ ដែលស្មើនឹង៣៣ភាគរយនៃប្រជាពលរដ្ឋខ្មែរតាំងមូល ។ ការពង្រឹងខាងផ្លូវផ្លូវច្បាប់ចំពោះជនអន្តោប្រវេសន៍នេះ ពុំមែនមានតែប្រទេសខ្មែរទេ គឺគេអនុវត្តគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក ដើម្បីរក្សាអធិបតេយ្យជាតិ និងបូរណភាពទឹកដី ហើយមិនអាចត្រូវចោទថា ជាប្រទេសប្រកាន់ជាតិសាសន៍ឡើយ ។

សង្ឃឹមថា ព្រះករុណាព្រះមហាក្សត្រខ្មែរ ព្រះអង្គនឹងជួយជម្រុញនូវសំណូមពរទាំងពីរខនេះទៅរាជរដ្ឋាភិបាលខ្មែរ ដើម្បីរាជរដ្ឋាភិបាលយកទៅពិចារណា ហើយសំរេចតាមការគួរ ស្របតាមនាទីរបស់ព្រះអង្គត្រង់មាត្រា៨នៃរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នចែងថា ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

វត្តខ្មែរកាណាដា, ថ្ងៃទី១៥ កុម្ភៈ ២០០៦
ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ

❑ ❑

❑

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**
**នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

ប្រគេន ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ
វត្តខ្មែរកាណាដា
7188 de NANCY, Montréal
Québec, H3R 2L7, Canada

ព្រះតេជព្រះគុណ ជាទីគោរពសក្ការៈ

ខ្ញុំព្រះករុណាបានទទួលរួចហើយ ចុតហ្មាយរបស់ព្រះតេជព្រះគុណ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០៦។

ខ្ញុំព្រះករុណា សូមអរព្រះគុណដ៏ជ្រាលជ្រៅ និងសូមសរសើរចំពោះព្រះហឫទ័យ ស្នេហាជាតិដ៏ប្រសើរថ្លៃថ្លារបស់ព្រះតេជព្រះគុណ ។

ខ្ញុំព្រះករុណាបានផ្ញើចុតហ្មាយរបស់ព្រះតេជព្រះគុណ ថ្វាយសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាជាតិ ដើម្បីព្រះតម្រិះនូវសំណើរបស់ព្រះតេជព្រះគុណ។

សូមព្រះតេជព្រះគុណ ទទួលនូវសេចក្តីគោរពសក្ការៈ អំពីខ្ញុំព្រះករុណា ។

ន សីហមុនី

**នរោត្តម សីហមុនី**

ភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៦